UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

# វិធីសាស្ត្រផ្អែកលើសិទ្ធិ ដែលត្រូវធ្វើកំណែទម្រង់

មួយឆ្នាំកន្លងមក អង្គការសហប្រជាជាតិបានរៀបចំរំលឹកទិវាសិទ្ធិមនុស្ស ក្រោមប្រធានបទថា "សំឡេងរបស់ខ្ញុំត្រូវបានរាប់!" បាទ អញ្ចឹងហើយ។ ក្នុងឱកាសទិវាសិទ្ធិមនុស្ស ២០១៣ យើងក្រឡេកមើលថយក្រោយទៅឆ្នាំដែលមានហេតុការណ៍ច្រើន ដែលមានសំឡេងទាមទារឲ្យគេរាប់ ហើយកំណែទម្រង់នៅក្នុងវិស័យខ្លះត្រូវបានផ្តួចផ្តើម។ ចំពោះគោលដៅអភិវឌ្ឍដ៏មហិច្ឆិតារបស់ប្រទេកម្ពុជា សមាសធាតុសំខាន់បីរបស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ចំពោះការអភិវឌ្ឍ ដូចជា គណនេយ្យភាព តម្លាភាព និង ការចូលរួម នឹងពង្រឹងឱកាសសម្រាប់កំណែទម្រង់ដោយជោគជ័យ។

ទីមួយ ផ្នែកជោគជ័យតម្រូវឲ្យមានយន្តការច្បាស់លាស់ពី **គណនេយ្យភាព**។ រដ្ឋ បាលសាធារណៈដែលមានគណនេយ្យភាព និង ប្រព័ន្ធតុលាការប្រសិទ្ធភាព និង ឯករាជ្យ គឺស្ថិតនៅក្នុងចំណោមសរសរស្តម្ភសំខាន់បំផុតនៃការគាំទ្រសម្រាប់សម្រេចនូវគោលដៅអភិវឌ្ឍធនធានមនុស្សជានិរន្តរនៅក្នុងលទ្ធិប្រជាធិបតេយ្យ សេរី។ ការដោះស្រាយវិវាទដោយសន្តិភាព និង ត្រឹមត្រូវ ផ្អែកលើប្រព័ន្ធតុលាការដែលទុកចិត្តបាន ដើម្បីឲ្យពលរដ្ឋ អ្នកវិនិយោគ និង បុគ្គលណាដែលស្វែងរកដំណោះស្រាយ អាចមានជំនឿថា រឿងក្តីរបស់គេ ទោះបីរឿងក្តីរដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ នឹងទទួលបានការវិនិច្ឆ័យក្តីស្របតាមពាក្យពេចន៍ និង ស្មារតីច្បាប់។ ផែនការសម្រាប់កំណែទម្រង់វិស័យយុត្តិធម៌ទូលំទូលាយ ដែលបន្ទាប់ពីការពិគ្រោះយោបល់ជាសាធារណៈដែលយើងយល់ថាត្រូវរៀបចំធ្វើឡើងឆាប់ៗអំពីបញ្ហានេះ កំពុងរង់ចាំធ្វើឡើងយ៉ាងខ្លាំង។

ប៉ុន្តែ គណនេយ្យភាព មិនត្រឹមតែនិយាយពីតុលាការប៉ុណ្ណោះទេ។ តម្លាភាពមានសារៈសំខាន់ណាស់សម្រាប់សេវាសាធារណៈគ្រប់លំដាប់ថ្នាក់។ ផ្នែកសំខាន់នៃស្មារតីទទួលខុសត្រូវដែលដំណើរការជាមួយគណនេយ្យភាព គឺជាការស្វែងយល់ ជាការគោរព និង ជាការពារសិទ្ធិមនុស្ស។ ចុងបញ្ចប់របៀបវារៈកំណែទម្រង់ជាតិនឹងទទួលបានផលប្រយោជន៍ ពីការពង្រឹងការអប់រំផ្អែកសិទ្ធិមនុស្សដល់មន្ត្រីរាជការសាធារណៈ។ អាចនិយាយបានថា យន្តការគណនេយ្យភាពចុងក្រោយនៅក្នុងលទ្ធិប្រជាធិបតេយ្យដែលកំពុងមាន គឺជាប្រអប់បោះឆ្នោត។ ភាពអាចសម្រេចទៅបាននៃរចនាសម្ព័ន្ធគណនេយ្យភាព

ដែលមានលទ្ធភាពការពារសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព នឹងពឹងផ្អែកដោយផ្នែកទៅលើកំណែទម្រង់ការបោះឆ្នោតដោយជោគជ័យ ដែលរដ្ឋាភិបាលបានប្តេជ្ញា ហើយករណីនេះត្រូវតែធ្វើឡើង និងតម្រូវឲ្យមានតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ទីពីរ វិធីសាស្ត្រផ្អែកលើសិទ្ធិទាមទារឲ្យមាន **តម្លាភាព**។ នៅពេលសាធារណជនទទួលដំណឹងពីខ្លឹមសារនៃថវិការដ្ឋ ប្រតិបត្តិការនៃទ្រព្យរដ្ឋ កម្មសិទ្ធិលើដីធ្លី ខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬ កម្រិតនៃអំពើពុករលួយនៅក្នុងសេវាសាធារណៈ គេអាចផ្តល់យោបល់ដែលមានប្រយោជន៍ ដែលជាថ្នូរវិញ នឹងអនុញ្ញាតឲ្យមានការធ្វើសេចក្តីសម្រេចដោយមានព័ត៌មានច្រើន។ ការខ្វះនូវចំណុចនេះនឹងមិនត្រឹមតែដករឿងហេតុដែលកំពុងមានបញ្ហាទាំងនោះពីប្រទេសជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដកការពិភាក្សាយ៉ាងផុសផុល និង គំនិតថ្មីៗដែលអាចកើតចេញពីចំណុចនេះទៀតផង។ ដោយហួសពីផលប្រយោជន៍ដែលតែងតែគិតគូរនោះ ការធ្វើឲ្យមានសិទ្ធិទទួលបានព័ត៌មានសំខាន់ៗ គឺជាផ្នែកសំខាន់នៃក្របខណ្ឌអភិបាលកិច្ចផ្អែកលើសិទ្ធិ។ ការធានាលើចំណុចនេះ ដូចជាតាមរយៈច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន នឹងជាសញ្ញាស្វាគមន៍នៃការប្តេជ្ញាចិត្តចំពោះតម្លាភាព។

សមាសធាតុសំខាន់ទីបីរបស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គឺ **ការចូលរួម** យ៉ាងផុសផុលនៅក្នុងការធ្វើសេចក្តីសម្រេច។ ចំណុចសំខាន់សម្រាប់ករណីនេះ គឺជាសិទ្ធិជាក់លាក់ផ្សេងៗទៀត ដែលតាមរយៈនេះការចូលរួមអាចធ្វើឡើងបាននៅក្នុងស្មារតីជាក់ស្តែង ជាពិសេសសិទ្ធិការជួបជុំដោយសន្តិវិធី និង សេរីភាពផ្នែកសមាគម និង ការសម្តែងមតិ។ ផ្តើមចេញពីអានុភាពនៃព្យុហយាត្រា ញត្តិ និងបាតុកម្មដែលឃើញមាននៅក្នុងឆ្នាំនេះ រួមទាំងព្រឹត្តិការណ៍មកដល់ថ្ងៃនេះ វាជាការជាក់ច្បាស់ថា សម្លេងរបស់ប្រជាជនខ្មែរ កំពុងខ្វំខ្វារ។ ក្នុងពេលជាមួយគ្នានេះដែរ ប្រសិនបើតម្រូវឲ្យមានវិធានការណាមួយដែលរឹតត្បិតចលនា ឬ អនុញ្ញាតឲ្យមានការប្រើប្រាស់កងកម្លាំង វិធានការទាំងនោះត្រូវធ្វើឡើងដោយអនុលោមយ៉ាងតឹងរ៉ឹងតាមល័ក្ខខ័ណ្ឌនៃភាពចាំបាច់ នីត្យានុកូលភាព និង សមាមាត្រដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ម៉្យាងវិញទៀត យន្តការសំខាន់សម្រាប់ការចូលរួមយ៉ាងផុសផុលក្នុងលទ្ធិប្រជាធិបតេយ្យ គឺជាស្ថាប័នតំណាងដែលបានបោះឆ្នោតជ្រើសរើស។ សភានឹងបំពេញតួនាទីនេះ នៅពេលរៀបចំធ្វើវេទិកា ឬ ពិគ្រោះយោបល់ជាសាធារណៈ មុននឹងអនុម័តច្បាប់។

ក្រសួងផ្សេងៗបានប្រកាសថា ពួកគេនឹងរៀបចំការពិគ្រោះយោបល់ជាសាធារណៈអំពីវិធីពង្រឹងសេវារបស់ខ្លួន។ គួរផ្តល់ការគាំទ្រដល់រៀបចំការពិគ្រោះយោបល់នេះនៅគ្រប់ក្រសួងជាទៀងទាត់ ដើម្បីធ្វើ

ឲ្យពួកគេក្តាប់បានទាំងអស់ និង អនុញ្ញាតពួកគេទទួលបានប្រយោជន៍យ៉ាងល្អប្រសើរពីជំនាញជាតិ និង អន្តរជាតិ។ ចុងបញ្ចប់ ការពិគ្រោះយោបល់ទាំងនេះ គួរតែមាននិយាយពីតម្លាភាព គណនេយ្យភាព និង ការចូលរួម។

ទិវាសិទ្ធិមនុស្សឆ្នាំនេះ ប្រារព្ធឡើងដើម្បីបិទឆ្នាំពិសេសនេះ។ សម្រាប់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៣ នេះ រៀបចំប្រារព្ធខួបលើកទី ២០ នៃការបង្កើតការការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស។ ពិភពលោកថ្មីៗនេះ យើងប្រារព្ធពិធីពីការបាត់បង់មេដឹកនាំមនុស្សជាតិដ៏អស្ចារ្យម្នាក់ ដែលគាត់ល្បីដោយសារគាត់ជាមនុស្សមិនគិតប្រយោជន៍ខ្លួនឯង ដោយការផ្តន្ទាទោសរបស់គាត់ និង ដោយសារបានផ្លាស់ប្តូរការសម្តែងមតិជាសកលអំពីសិទ្ធិមនុស្ស។ គាត់ឈ្មោះ នែលសុន ម៉ាន់ដេឡា មានអត្ថន័យប្រហាក់ប្រហែលនឹងគោលការណ៍ដែលកាលពី ៦៥ ឆ្នាំ មុន មកដល់ថ្ងៃនេះ គេឃើញមានពាក្យនេះនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

សម្រាប់ប្រទេសកម្ពុជានៅទីនេះ យើងមិនអាចរីករាយនឹងការកែតម្រូវអយុត្តិធម៌យូរអង្វែងមួយចំនួនខណៈពេលបញ្ហាផ្សេងទៀតនៅតែត្រូវដោះស្រាយនោះទេ។ មេរៀនមួយដែលបានសិក្សាពីកម្មវិធីផ្អែកលើសិទ្ធិគ្រប់ទីកន្លែង គឺថា ដំណើរការមានបញ្ហាជាច្រើនដូចជា ឆន្ទៈ ឬ លទ្ធផល។ នៅពេលដំណើរការកែទម្រង់ផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ឱកាសទទួលបានជោគជ័យកើនឡើងជាច្រើនជាបណ្តើរៗ។ អង្គការសហប្រជាជាតិត្រៀមខ្លួនរួចជាស្រេចក្នុងការជួយ។ ម៉ាន់ដេឡា មិនទាមទារអ្វីដែលតិចតួចនោះទេ។

**វ៉ាន់ ហ៊ីលី**
**អ្នកតំណាង**
**ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា**